អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

៥ ឆ្នាំក្រោយមក

# របាយការណ៍ស្តីពីទិន្នន័យដើមគ្រា ឆ្នាំ ២០២០



ខែមីនា ឆ្នាំ ២០២២

អ្នកនិពន្ធ៖ ទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធី ASEAN-ACT

សេចក្តីបដិសេធ៖ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងត្រូវបានអនុវត្តដោយក្រុមហ៊ុនខាងណូអភិវឌ្ឍន៍អន្តរជាតិ (Cardno International Development) ដែលគឺជាក្រុមហ៊ុន DT Global Company មួយ។ ឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈដែលបានសម្តែងនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនមែនគឺជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីទេ។

# អារម្ភកថា

ឆ្នាំ ២០២០ គឺជាខួប ៥ ឆ្នាំនៃការចុះហត្ថលេខាលើអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ហៅកាត់ថា អនុសញ្ញា)។

កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) គឺជាភាពជាដៃគូរយៈពេល ១០ ឆ្នាំ ទទួលបានថវិកាគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី ដែលធ្វើការជាមួយរដ្ឋសមាជិកអាស៊ាន ដើម្បីគាំទ្រដល់ការអនុវត្តអនុសញ្ញានេះ ជាពិសេសកាតព្វកិច្ចទាំងឡាយដែលមានគោលបំណងការពារ និងគោរពសិទ្ធិរបស់ជនរងគ្រោះ ក៏ដូចជាលើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសង្គម។

ដើម្បីអបអរសាទរខួប ៥ ឆ្នាំនៃអនុសញ្ញានេះ របាយការណ៍នេះពិនិត្យមើលរបាយការណ៍ប្រចាំឆ្នាំស្តីពីអំពើជួញដូរមនុស្ស (TIP) ដែលរដ្ឋសមាជិកអាស៊ានបានចេញផ្សាយកាលពីឆ្នាំ ២០២០។

របាយការណ៍នេះបង្ហាញពីវិធីសាស្រ្ត ដែលរដ្ឋសមាជិកអាស៊ានប្រើប្រាស់សម្រាប់រាយការណ៍ពីការអនុវត្តកាតព្វកិច្ចនៅក្នុងអនុសញ្ញានេះ និងបង្ហាញពីលទ្ធផល និងអនុសាសន៍សំខាន់ៗ ដើម្បីផ្តល់ជាជំនួយស្មារតីសម្រាប់ការតាក់តែងគោលនយោបាយ និងការសហការនាពេលអនាគត ដើម្បីគាំទ្រដល់ការសម្រេចគោលដៅនៃអនុសញ្ញានេះ។

យើងសង្ឃឹមថាការបោះពុម្ពផ្សាយរបាយការណ៍ទិន្នន័យដើមគ្រាឆ្នាំ ២០២០ ដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំស្តីពីអំពើជួញដូរមនុស្សរបស់រដ្ឋសមាជិកអាស៊ាន ដែលធ្វើដោយកម្មវិធី ASEAN-ACT នឹងនាំឱ្យមានការបង្កើនតម្លាភាពក្នុងរបាយការណ៍ប្រចាំឆ្នាំនៃប្រទេសជាសមាជិកអាស៊ាន ដែលបង្ហាញឱ្យឃើញពីសមិទ្ធផលប្រចាំឆ្នាំ ក៏ដូចជាបញ្ហាប្រឈមដែលនៅកំពុងបន្តកើតមានឡើង ខណៈពេលដែលបណ្តាប្រទេសទាំងនេះព្យាយាមអនុវត្តអនុសញ្ញានេះឱ្យបានពេញលេញប្រកបដោយសង្គតិភាព។

កម្មវិធី ASEAN-ACT នឹងធ្វើបច្ចុប្បន្នភាពរបាយការណ៍នេះជារៀងរាល់ឆ្នាំ ក្នុងរយៈពេលនៃកម្មវិធីទាំងមូល (២០១៨-២០២៨) ក៏ដូចជាបន្តធ្វើការងារជាមួយអាស៊ាន និងរដ្ឋសមាជិកអាស៊ាន ដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញា ACTIP។

បណ្ឌិត Lucia Pietropaoli
ប្រធានក្រុមនៃកម្មវិធី ASEAN-ACT

# មាតិកា


១ សង្ខេបៈ លទ្ធផល

២ សង្ខេបៈ អនុសាសន៍

៣ អនុសញ្ញា

៤ ២០២០ - ៥ ឆ្នាំក្រោយពេលចុះហត្ថលេខា

៥ ហេតុអ្វីបានជាទិន្នន័យមានសារៈសំខាន់សម្រាប់ការអនុវត្តអភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះក្នុងករណីជួញដូរមនុស្ស?

៦ តើជនរងគ្រោះដោយអំពើជួញដូរមនុស្សចង់ដឹងអ្វីខ្លះ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវក្នុងការធ្វើជាសាក្សី?

៧ ការបោះពុម្ពផ្សាយទិន្នន័យអំពើជួញដូរមនុស្សនៃបណ្តាប្រទេសជាសមាជិកអាស៊ាន មានសារៈសំខាន់សម្រាប់

៨ អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះក្នុងករណីជួញដូរមនុស្សៈ សូចនាករសមិទ្ធិគន្លឹះចំនួន ២២ ពាក់ព័ន្ធនឹងទិន្នន័យ

៩ សង្ខេបឆ្នាំ ២០២០
(១) តម្លាភាព
(២) ទិន្នន័យនិន្នាការអំពើជួញដូរមនុស្ស
(៣) ទិន្នន័យគន្លឹះស្តីពីការគ្រប់គ្រងករណីជួញដូរមនុស្ស
(៤) ករណីជួញដូរមនុស្សនៅតុលាការដែលត្រូវបានបញ្ចប់
(៥) ការផ្តល់សំណងដល់ជនរងគ្រោះ
(៦) ជំនួយផ្លូវច្បាប់សម្រាប់ជនរងគ្រោះ
(៧) ការជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធវីដេអូសម្រាប់ការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះ
(៨) ទិន្នន័យបែងចែកតាមស្ថានភាពរបស់ជនរងគ្រោះ
(១១) តម្លាភាពស្តីពីមន្ត្រីដែលសមគំនិតក្នុងករណីជួញដូរមនុស្ស
(១២) តម្លាភាពនៃការសម្រេចចិត្តលើករណីជួញដូរមនុស្ស

១៥ ឧបសម្ព័ន្ធទី ១ៈ សូចនាករគន្លឹះចំនួន ២២ ស្តីពីអំពើជួញដូរមនុស្ស
សូចនាករ ១-៥
សូចនាករ ៦-៩
សូចនាករ ១០-១២
សូចនាករ ១៣-១៦
សូចនាករ ១៧-២២

២១ សេចក្តីថ្លែងអំណរគុណ

# សង្ខេបៈ លទ្ធផល

ភាគីនៃអនុសញ្ញា ACTIP ចំនួន ៣ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីអំពើជួញដូរមនុស្សដែលគេអាចរកបានជាសាធារណៈក្នុងឆ្នាំ ២០២១។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ២ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យនិន្នាការសម្រាប់សូចនាករគន្លឹះ ស្តីពីអំពើជួញដូរមនុស្សក្នុងរយៈពេល ៣-៥ ឆ្នាំ។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ២ ក្នុងចំណោម ១០ អាចរាយការណ៍ពីសូចនាករចំនួន ៨ ក្នុងចំណោមសូចនាករនានា ស្តីពីការគ្រប់គ្រងករណីជួញដូរមនុស្ស។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ១ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីលទ្ធផលនៃសំណុំរឿងនៅសាលាដំបូងដែលត្រូវបានបញ្ចប់កាលពីឆ្នាំ ២០២០។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ២ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនករណីជួញដូរមនុស្សដែលបានបញ្ចប់នីតិវិធីដោយសាលាដំបូងក្នុងឆ្នាំ ២០២០។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ០ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីភាគរយសំណុំរឿងជួញដូរមនុស្ស ដែលត្រូវបានបញ្ចប់កាលពីឆ្នាំ ២០២០ ដែលនៅក្នុងនោះ ជនរងគ្រោះបានទទួលសំណង។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ២ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនសំណុំរឿងជួញដូរមនុស្ស ដែលបានដាក់ទៅតុលាការ ហើយដែលជនរងគ្រោះបានទទួលជំនួយផ្លូវច្បាប់។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ១ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនជនរងគ្រោះដែលអាចផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូនៅមុនពេលសវនាការ ក្នុងតុលាការ កាលពីឆ្នាំ ២០២០។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ៤ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមភេទ។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ៤ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមអាយុ។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ០ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមពិការភាព។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ២ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីអំពើជួញដូរមនុស្ស ដែលបង្ហាញពីចំនួននៃការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសមន្ត្រីដែលសមគំនិតក្នុងករណីជួញដូរមនុស្ស។

ភាគីនៃអនុសញ្ញា ACTIP ចំនួន ១ ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយតាមប្រព័ន្ធអនឡាញនូវសេចក្តីសម្រេចរបស់តុលាការស្តីពីអំពើជួញដូរមនុស្សដោយមានការរក្សាអនាមិកភាព កាលពីឆ្នាំ ២០២០។

# សង្ខេបៈ អនុសាសន៍

១ កម្មវិធី ASEAN-ACT ដោយសហការជាមួយនឹងអាស៊ាន ជួយដល់ភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីអំពើជួញដូរមនុស្សរបស់ខ្លួន។

២ កម្មវិធី ASEAN-ACT ធ្វើការងារជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីជួយបង្ហាញពីទិន្នន័យនិន្នាការ ដែលបង្ហាញពីការវិវដ្តពីមួយឆ្នាំទៅមួយឆ្នាំនៃទិន្នន័យគន្លឹះស្តីពីអំពើជួញដូរមនុស្ស ដើម្បីឱ្យយល់កាន់តែច្បាស់ពីនិន្នាការនៃករណីជួញដូរមនុស្ស។

៣ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីកែលម្អការប្រមូល និងវិភាគទិន្នន័យអំពើជួញដូរមនុស្ស។

៤ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយទិន្នន័យនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស ដូចជាសំណុំរឿងជួញដូរមនុស្សដែលត្រូវបានដាក់ទៅតុលាការ និងដែលត្រូវបានបញ្ចប់នីតិវិធីនៅក្នុងឆ្នាំដែលបានរាយការណ៍ព្រមទាំងលទ្ធផលនៃសំណុំរឿងទាំងនេះ។

៥ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយទិន្នន័យនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស ដូចជាការគាំទ្រដែលផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងនោះ មានការផ្តល់សំណង ជំនួយផ្លូវច្បាប់ និងការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូនៅមុនពេលសវនាការជាដើម។

៦ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីប្រមូល វិភាគ និងបោះពុម្ពផ្សាយទិន្នន័យពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយបែងចែកតាមភេទ អាយុ និងពិការភាព។

៧ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយរបាយការណ៍អំពើជួញដូរមនុស្សប្រចាំឆ្នាំរបស់ភាគីទាំងនោះ ដូចជាចំនួននៃការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសមន្ត្រីដែលសមគំនិតក្នុងករណីជួញដូរមនុស្ស នៅក្នុងអំឡុងពេលនៃការរាយការណ៍។

៨ កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបង្កើនតម្លាភាពពាក់ព័ន្ធនឹងការសម្រេចចិត្តក្នុងសំណុំរឿងជួញដូរមនុស្សតាមរយៈការបោះពុម្ពផ្សាយព័ត៌មានមួយចំនួននៃសេចក្តីសម្រេច។



# អនុសញ្ញា

កាលពីខែវិច្ឆិកា ឆ្នាំ ២០១៥ ប្រជាជាតិអាស៊ានទាំង ១០ បានចុះហត្ថលេខាលើអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ហៅកាត់ថា អនុសញ្ញា)។

សេចក្តីផ្តើមនៃអនុសញ្ញានេះ លើកឡើងថា៖ ហត្ថលេខីទទួលស្គាល់ថា ការជួញដូរមនុស្ស គឺជាការរំលោភបំពានសិទ្ធិមនុស្ស និងជាបទល្មើសលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

ហត្ថលេខីក៏ទទួលស្គាល់ផងដែរថា អំពើជួញដូរមនុស្សបង្កឡើងដោយសារកត្តាជាច្រើនគួបផ្សំគ្នា ដូចជា អំពើពុករលួយក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ភាពក្រីក្រ អស្ថេរភាពសេដ្ឋកិច្ច ប្រព័ន្ធច្បាប់ពុំមានប្រសិទ្ធភាព ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងតម្រូវការដែលជំរុញឱ្យមានការកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាពជាពិសេសស្ត្រី និងកុមារ ដែលបណ្តាលឱ្យមានការជួញដូរមនុស្ស ហើយត្រូវមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះករណីជួញដូរមនុស្ស។

ហត្ថលេខីបានទទួលស្គាល់ពីភាពចាំបាច់ក្នុងការបង្កើតនូវលិខិតទុបករណ៍ថ្នាក់តំបន់មួយ ដើម្បីឆ្លើយតបចំពោះអំពើជួញដូរមនុស្សក្នុងទម្រង់ជាក្របខ័ណ្ឌច្បាប់ ដើម្បីឱ្យប្រជាជាតិនៅអាស៊ីអាគ្នេយ៍ចាត់វិធានការក្នុងក្របខ័ណ្ឌតំបន់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងចំពោះអំពើជួញដូរមនុស្ស រួមនឹងការផ្តល់ការការពារ និងជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ។

អនុសញ្ញានេះដាក់ចេញនូវកាតព្វកិច្ចតាមច្បាប់ [ដើម្បី...] ជួយដល់រដ្ឋសមាជិកអាស៊ានក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈម អាទិភាព និងយុទ្ធសាស្ត្រផ្សេងៗគ្នានៅតាមប្រទេសនីមួយៗ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

# ២០២០ – ៥ ឆ្នាំក្រោយពីពេលចុះហត្ថលេខា

អនុសញ្ញានេះដាក់ចេញនូវអភិក្រមដែលមានការសហការគ្នា ដើម្បីកសាងការឆ្លើយតបនៅក្នុងថ្នាក់តំបន់ឱ្យបានរឹងមាំ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក៏ដូចជាពង្រឹងកិច្ចការពារ និងការផ្តល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

ការអនុវត្តអនុសញ្ញានេះ ពឹងផ្អែកលើការប្រមូល ការវិភាគ និងការចែករំលែកទិន្នន័យជួញដូរមនុស្ស ដើម្បីធ្វើការកំណត់ថាតើមានការបំពេញតាមកាតព្វកិច្ចដែលចែងនៅក្នុងអនុសញ្ញានេះដែរឬទេ។

ការបោះពុម្ពផ្សាយប្រកបដោយតម្លាភាពនូវរបាយការណ៍ប្រចាំឆ្នាំថ្នាក់ជាតិ ស្តីពីអំពើជួញដូរមនុស្សរបស់ប្រទេសនីមួយៗ ធានាថាស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ក្នុងរដ្ឋសមាជិកអាស៊ាន ដែលធ្វើការងារ ដើម្បីឈានទៅសម្រេចគោលដៅនៃអនុសញ្ញានេះ និងដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះ មានព័ត៌មានដូចគ្នាសម្រាប់រៀបចំ និងកែលម្អការផ្តល់សេវារបស់ខ្លួន។

គោលដៅ គឺដើម្បីបញ្ចៀសការប្រើប្រាស់អភិក្រមប្រមូលទិន្នន័យ ដែលមានលក្ខណៈបែកខ្ញែកគ្នាទៅតាមស្ថាប័ននីមួយៗ ដែលមិនផ្តល់នូវរូបភាពពេញលេញពីសកម្មភាពអនុវត្តអនុសញ្ញានេះក្នុងប្រទេសនីមួយៗ។





# ហេតុអ្វីបានជាទិន្នន័យមានសារៈសំខាន់ និងចាំបាច់សម្រាប់ការអនុវត្ត អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះក្នុងសំណុំរឿងជួញដូរមនុស្ស?

រដ្ឋសមាជិកអាស៊ានបានចាត់ទុកការយកចិត្តទុកដាក់ចំពោះជនរងគ្រោះនៅគ្រប់ដំណាក់កាលទាំងអស់នៃសំណុំរឿងជួញដូរមនុស្សជាអាទិភាព។

ការចោទប្រកាន់លើជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស ពឹងផ្អែកច្រើនលើការត្រៀមរៀបចំឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សធ្វើជាសាក្សីក្នុងនីតិវិធីព្រហ្មទណ្ឌ និងបង្ហាញពីភ័ស្តុតាងរំលឹកឡើងវិញពីអ្វីដែលបានកើតឡើងចំពោះពួកគេ។ នេះអាចជាបទពិសោធន៍ដែលបង្កការប៉ះទង្គិចផ្លូវចិត្ត ហើយជនរងគ្រោះចង់ធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានដែលទទួលបានគ្រប់ជ្រុងជ្រោយ ថាតើពួកគេនឹងធ្វើជាសាក្សីដែរឬទេ។

ប្រសិនបើពុំមានទិន្នន័យជាតិស្តីពីសំណុំរឿងជួញដូរមនុស្ស ដែលពន្យល់ពីលទ្ធផលសម្រាប់ទាំងជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស និងទាំងជនរងគ្រោះនោះទេ ជនរងគ្រោះពុំអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវឡើយ។

តម្លាភាពនៃរបាយការណ៍ជាតិប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្សក្នុងតំបន់អាស៊ានទាំងមូល បង្ហាញពីការប្តេជ្ញាចិត្តរបស់តំបន់នេះក្នុងការអនុវត្តអនុសញ្ញានេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ។

គេសង្ឃឹមថា ការបង្ហាញពីចំណាត់ការលើករណីជួញដូរមនុស្សនៅក្នុងតំបន់អាស៊ាន និងការយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលធ្វើជាសាក្សីក្នុងសំណុំរឿងទាំងនេះ នឹងមានភាពប្រសើរចំពោះការប្រតិបត្តិចំពោះជនរងគ្រោះ ក៏ដូចជាលទ្ធផលដែលពួកគេនឹងទទួលបាន។ នេះអាចលើកទឹកចិត្តឱ្យជនរងគ្រោះកាន់តែច្រើនផ្តល់សក្ខីកម្មក្នុងសំណុំរឿងជួញដូរមនុស្សនាពេលអនាគត។

# តើជនរងគ្រោះដោយអំពើជួញដូរមនុស្សចង់ដឹងអ្វីខ្លះ ដើម្បីធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ថាតើពួកគេនឹងធ្វើជាសាក្សីដែរ ឬទេ?



# ប្រជាជាតិអាស៊ាន

## បោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស របស់ប្រជាជាតិអាស៊ាន មានសារៈសំខាន់សម្រាប់

### រដ្ឋសមាជិកអាស៊ាន

ដែលបានចុះហត្ថលេខាលើ អនុសញ្ញាអាស៊ានស្តីពីការ ប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារក្នុង ឆ្នាំ ២០១៥

រដ្ឋសមាជិកទាំងនេះបាន សន្យាថានឹងសហការគ្នាក្នុង ការប្រយុទ្ធប្រឆាំងនឹងអំពើ ជួញដូរមនុស្ស។

ការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើ ជួញដូរមនុស្ស ផ្តល់នូវមូលដ្ឋានភ័ស្តុតាង ដើម្បីវាយតម្លៃ ថាតើការងាររបស់រដ្ឋ សមាជិកទាំងនេះទទួលបាន ផលដែរឬទេ។

### ស្ថាប័នរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល

ដែលផ្តល់នូវជម្រកសុវត្ថិភាព ជំនួយផ្លូវច្បាប់ សេវា វេជ្ជសាស្ត្រ និងសេវាផ្តល់ ប្រឹក្សាដល់ជនរងគ្រោះ

ស្ថាប័នទាំងនេះរួម ចំណែកដល់ការប្រមូល និងវិភាគទិន្នន័យស្តីពីអំពើ ជួញដូរមនុស្ស ដើម្បីផ្តល់ សេវានានាប្រកបដោយ ប្រសិទ្ធភាពដល់ជនរង គ្រោះដោយអំពើជួញដូរ មនុស្ស។

### ជនរងគ្រោះដោយ អំពើជួញដូរមនុស្ស

ជនរងគ្រោះត្រូវការ ព័ត៌មានមួយចំនួន ដើម្បីធ្វើការសម្រេច ចិត្តឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ថាតើពួកគេត្រូវ បង្ហាញភ័ស្តុតាងក្នុង សំណុំរឿងជួញដូរ មនុស្សដែរឬទេ។

### ស្ថាប័នយុត្តិធម៌ នៅក្នុងប្រទេស

ដូចជានគរបាល អយ្យការ និង តុលាការ

ដោយសារពួកគេ ពឹងផ្អែកលើសាក្សី និងជនរងគ្រោះ ក្នុង ការផ្តល់ភ័ស្តុតាងក្នុង សំណុំរឿងជួញដូរ មនុស្ស។

# អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ ក្នុងសំណុំរឿងជួញដូរមនុស្ស៖

## សូចនាករសមិទ្ធិគន្លឹះចំនួន ២២ ពាក់ព័ន្ធនឹងទិន្នន័យ

រដ្ឋសមាជិកអាស៊ានបានចាត់ទុក ការយកចិត្តទុកដាក់ចំពោះជនរងគ្រោះក្នុងសំណុំរឿងជួញដូរមនុស្ស ថាជាអាទិភាពមួយនៅក្នុងអនុសញ្ញានេះ។

ប្រទេសជាសមាជិកអាស៊ានភាគច្រើន បានប្រមូលទិន្នន័យជាច្រើនអំពីករណីជួញដូរមនុស្សរួចមកហើយ។ ទោះជាយ៉ាងនេះក្តី រដ្ឋសមាជិកអាស៊ាន អាចពិចារណាបង្ហាញពីសូចនាករទិន្នន័យទាំង ២២ ខាងក្រោម នៅក្នុងរបាយការណ៍ជាតិប្រចាំឆ្នាំរបស់ខ្លួន ស្តីពីអំពើជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ានភាគច្រើន កំពុងប្រមូលទិន្នន័យទាំងនេះរួចទៅហើយ ហើយការដាក់បញ្ចូលទិន្នន័យទាំងនេះទៅក្នុងរបាយការណ៍ជាតិប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស និងបង្ហាញឱ្យឃើញពីស្ថានភាព ដែលរដ្ឋសមាជិកកំពុងអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងអនុសញ្ញានេះ ក៏ដូចជាបទពិសោធន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងការអនុវត្តនីតិវិធីទាំងនេះ ប្រសិនបើពួកគេសម្រេចចិត្តធ្វើជាសាក្សីក្នុងនីតិវិធីព្រហ្មទណ្ឌ ឬដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារសំណង។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ (KPIs) ខាងក្រោម គាំទ្រដល់គោលការណ៍ និងការណែនាំ ដែលត្រូវបានដាក់ចេញជាអនុសាសន៍ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស ដែលរៀបចំដោយឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក៏ដូចជាសូចនាករយកចិត្តទុកដាក់ចំពោះជនរងគ្រោះចំនួន ៨ និងគោលការណ៍ណែនាំស្តីពីការអនុវត្តសូចនាករទាំងនេះ ដែលរៀបចំឡើងដោយកម្មវិធី ASEAN-ACT។

ការពិភាក្សាលម្អិតបន្ថែមទៀត អំពីសូចនាករសមិទ្ធិគន្លឹះ (KPIs) ពាក់ព័ន្ធនឹងទិន្នន័យទាំង ២២ អាចរកបាននៅក្នុងឧបសម្ព័ន្ធទី ១ និងកញ្ចប់ឧបករណ៍របស់កម្មវិធី ASEAN-ACT ស្តីពីសូចនាករសមិទ្ធិគន្លឹះ ស្តីពីទិន្នន័យអំពើជួញដូរមនុស្ស៖ កសាងមូលដ្ឋានភស្តុតាងសម្រាប់អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះដោយសារអំពើជួញដូរមនុស្សក្នុងតំបន់អាស៊ាន។



# សង្ខេបឆ្នាំ ២០២០

លទ្ធផលរកឃើញខាងក្រោមនេះ គឺផ្អែកតាមការពិនិត្យលើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស ដែលបោះពុម្ពផ្សាយតាមប្រព័ន្ធអនឡាញ ដោយរដ្ឋសមាជិកអាស៊ានចំនួន ៤ ក្នុងចំណោម ១០ ដែលជាភាគីនៃអនុសញ្ញានេះ។

របាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្សទាំងនេះអាចរកបានតាមរយៈគេហទំព័រដៃគូរបស់កម្មវិធី ASEAN-ACT៖ aseanactpartnershiphub.com


កម្ពុជា


ឥណ្ឌូនេស៊ី


ហ្វីលីពីន


ថៃ



# ១ តម្លាភាព

ភាគី ៣ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីអំពើជួញដូរមនុស្សដែលគេអាចរកបានជាសាធារណៈក្នុងឆ្នាំ ២០២១៖ កម្ពុជា, ហ្វីលីពីន, ថៃ។

**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT សហការជាមួយនឹងអាស៊ានជួយដល់ភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីអំពើជួញដូរមនុស្សរបស់ខ្លួន។**

# ២ ទិន្នន័យនិន្នាការនៃអំពើជួញដូរមនុស្ស

ភាគី ២ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យនិន្នាការសម្រាប់សូចនាករគន្លឹះ ស្តីពីអំពើជួញដូរមនុស្សក្នុងរយៈពេល ៣-៥ ឆ្នាំ ដើម្បីផ្តល់ឱ្យស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិលនូវមូលដ្ឋានភ័ស្តុតាងសម្រាប់រៀបចំគោលនយោបាយ និងកម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស៖ ថៃ និងឥណ្ឌូនេស៊ី។

**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT ធ្វើការងារជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីជួយបង្ហាញពីទិន្នន័យនិន្នាការ ដែលបង្ហាញពីការវិវដ្តពីមួយឆ្នាំទៅមួយឆ្នាំនៃទិន្នន័យគន្លឹះស្តីពីអំពើជួញដូរមនុស្ស ដើម្បីឱ្យយល់កាន់តែច្បាស់ពីនិន្នាការនៃករណីជួញដូរមនុស្ស។**



## ៣ ទិន្នន័យគន្លឹះស្តីពីការគ្រប់គ្រងករណីអំពើជួញដូរមនុស្ស

ភាគី ២ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ អាចរាយការណ៍ពីសូចនាករចំនួន ៤ ក្នុងចំណោមសូចនាករនានា ស្តីពីការគ្រប់គ្រងករណីជួញដូរមនុស្ស ពាក់ព័ន្ធនឹងការស៊ើបអង្កេត ការចោទប្រកាន់ ករណីដែលស្ថិតនៅសាលាដំបូង និងសាលាឧទ្ធរណ៍ និងរយៈពេលគិតជាមធ្យមសម្រាប់អនុវត្តនីតិវិធីនៃសំណុំរឿងជួញដូរមនុស្ស៖ ឥណ្ឌូនេស៊ី និងថៃ។



**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីកែលម្អការប្រមូល និងវិភាគទិន្នន័យអំពើជួញដូរមនុស្ស។**




## ៤ សំណុំរឿងអំពើជួញដូរមនុស្សក្នុងនីតិវិធីតុលាការដែលត្រូវបានបញ្ចប់

ភាគី ១ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនករណីជួញដូរមនុស្សដែលបានបញ្ចប់នីតិវិធីដោយសាលាដំបូងក្នុងឆ្នាំ ២០២០៖ ថៃ។



ខណៈពេលដែលភាគី ២ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនករណីជួញដូរមនុស្សដែលបានបញ្ចប់នីតិវិធីដោយសាលាដំបូងក្នុងឆ្នាំ ២០២០៖ ឥណ្ឌូនេស៊ីបានបញ្ចប់សំណុំរឿងចំនួន ២០០ ករណី និងប្រទេសថៃ ចំនួន ១៩៩ ករណី។



**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយទិន្នន័យនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស ដូចជាសំណុំរឿងជួញដូរមនុស្សដែលត្រូវបានដាក់ទៅតុលាការ និងត្រូវបានបញ្ចប់នីតិវិធី និងទទួលបានលទ្ធផលនៅក្នុងឆ្នាំរាយការណ៍។**

# ៥ សំណងដល់ជនរងគ្រោះ

ភាគី ០ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីភាគរយសំណុំរឿងជួញដូរមនុស្ស ដែលត្រូវបានបញ្ចប់កាលពីឆ្នាំ ២០២០ ក្នុងនោះជនរងគ្រោះបានទទួលសំណងពីមូលនិធិផ្តល់សំណងនៅថ្នាក់ជាតិ ឬបដិទាន/សំណងខូចខាតពីអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។



៩ ជនរងគ្រោះទទួលបានសំណងជំងឺចិត្ត/បដិទាន/សំណងការខូចខាត

១០ ការផ្តល់ការគាំទ្រដល់ជនរងគ្រោះ៖ ជំនួយផ្នែកច្បាប់

១១ ការផ្តល់ការគាំទ្រដល់ជនរងគ្រោះ ៖ ការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូនៅមុនពេលសវនាការ

# ៦ ជំនួយផ្លូវច្បាប់ដល់ជនរងគ្រោះ

ភាគី ២ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនសំណុំរឿងជួញដូរមនុស្ស ដែលបានដាក់ទៅតុលាការ ហើយដែលជនរងគ្រោះបានទទួលជំនួយផ្លូវច្បាប់៖ កម្ពុជា និងឥណ្ឌូនេស៊ី។



# ៧ ការផ្តល់សក្ខីកម្មជាមុនពីជនរងគ្រោះតាមប្រព័ន្ធវីដេអូ

ភាគី ១ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យស្តីពីចំនួនជនរងគ្រោះដែលអាចផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូនៅមុនពេលសវនាការក្នុងតុលាការកាលពីឆ្នាំ ២០២០៖ ថៃ។



**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយទិន្នន័យនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីអំពើជួញដូរមនុស្ស ដូចជាការគាំទ្រដែលផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងនោះមានដូចជា សំណង ជំនួយផ្លូវច្បាប់ និងការផ្តល់សក្ខីកម្មតាមប្រព័ន្ធវីដេអូនៅមុនពេលសវនាការជាដើម។**

# ៨ ទិន្នន័យបែងចែកតាមស្ថានភាពជនរងគ្រោះ

៩

ភាគី ៤ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមភេទ៖ កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ។



១០

ភាគី ៤ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមអាយុ៖ កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ។



ភាគី ០ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយទិន្នន័យជនរងគ្រោះដោយបែងចែកតាមពិការភាព។



**អនុសាសន៍៖**
**កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីប្រមូលវិភាគ និងបោះពុម្ពផ្សាយទិន្នន័យពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយបែងចែកតាមភេទ អាយុ និងពិការភាព។**









## ១១ តម្លាភាពអំពីមន្ត្រីដែលសមគំនិត

ភាគី ២ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ២០២០ ស្តីពីអំពើជួញដូរមនុស្ស ដែលបង្ហាញពីចំនួនការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសមន្ត្រីដែលសមគំនិតក្នុងករណីជួញដូរមនុស្ស៖ ថៃ និងហ្វីលីពីន។

**អនុសាសន៍៖**
កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបោះពុម្ពផ្សាយរបាយការណ៍អំពើជួញដូរមនុស្សប្រចាំឆ្នាំរបស់ភាគីទាំងនោះ ដូចជាចំនួនការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសមន្ត្រីដែលសមគំនិតក្នុងករណីជួញដូរមនុស្សនៅអំឡុងពេលនៃការរាយការណ៍។

## ១២ តម្លាភាពនៃសេចក្តីសម្រេចក្នុងសំណុំរឿងជួញដូរមនុស្ស

ភាគី ១ នៃអនុសញ្ញា ACTIP ក្នុងចំណោម ១០ បានបោះពុម្ពផ្សាយតាមប្រព័ន្ធអនឡាញនូវសេចក្តីសម្រេចរបស់តុលាការស្តីពីអំពើជួញដូរមនុស្សដោយមានការរក្សាអនាមិកភាពកាលពីឆ្នាំ ២០២០៖ ប្រព័ន្ធទិន្នន័យសាលក្រមតុលាការកំពូលឥណ្ឌូនេស៊ី។

**អនុសាសន៍៖**
កម្មវិធី ASEAN-ACT ធ្វើការជាមួយនឹងភាគីនៃអនុសញ្ញា ACTIP ដើម្បីបង្កើនតម្លាភាពពាក់ព័ន្ធនឹងការសម្រេចចិត្តក្នុងសំណុំរឿងជួញដូរមនុស្សតាមរយៈការបោះពុម្ពផ្សាយព័ត៌មានមួយចំនួននៃសេចក្តីសម្រេច។



# ឧបសម្ព័ន្ធទី ១
## សូចនាករគន្លឹះចំនួន ២២ ពាក់ព័ន្ធនឹងទិន្នន័យ

កម្មវិធី ASEAN-ACT បានរៀបចំកញ្ចប់ឧបករណ៍អំពីរបៀបរាយការណ៍ពីសូចនាករគន្លឹះទាំង ២២ ពាក់ព័ន្ធនឹងទិន្នន័យជួញដូរមនុស្សដែលបង្ហាញផងដែរនូវឧទាហរណ៍អំពីរបៀបដែលប្រទេសអាស៊ាន បានឆ្លើយតបចំពោះកាតព្វកិច្ចរាយការណ៍ទាំងនេះ។

ឧបសម្ព័ន្ធនៃកញ្ចប់ឧបករណ៍នេះ ផ្តល់ព័ត៌មានអំពីរបៀបបង្ហាញទិន្នន័យនិន្នាការ សម្រាប់សូចនាករគន្លឹះពាក់ព័ន្ធនឹងទិន្នន័យអំពើជួញដូរមនុស្ស។

សៀវភៅណែនាំដែលមានចំណងជើងថា៖ ដំណើរការការអនុវត្តល្អ ក្នុងការប្រមូលទិន្នន័យអំពើជួញដូរមនុស្ស (Operationalizing Good Practice in TIP Data Collection) ជាសៀវភៅណែនាំដែលរៀបរាប់លម្អិតពីគ្រប់ផ្នែកទាំងអស់នៃការប្រមូលទិន្នន័យអំពើជួញដូរមនុស្ស ដោយបោះពុម្ពផ្សាយដោយវិទ្យាស្ថានណិកស៊ឹស (Nexus Institute) ក្នុងឆ្នាំ ២០១៩ និងជាឯកសារមគ្គុទេសក៍ដ៏មានតម្លៃ សម្រាប់បណ្តាប្រទេសនានាដែលចង់បានឯកសារណែនាំជាជំហានៗ។

កម្មវិធី ASEAN-ACT នឹងបន្តផ្តល់ជំនួយដល់រដ្ឋសមាជិកអាស៊ាន ដើម្បីពង្រឹងការរាយការណ៍របស់ខ្លួនអំពីការអនុវត្តកាតព្វកិច្ច ដែលមានចែងនៅក្នុងអនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។





# សូចនាករ ១-៥




## ប្រធានបទ ៖ ទិន្នន័យស្តីពីការគ្រប់គ្រងសំណុំរឿង ពីនគរបាល អយ្យការ និងតុលាការ

### ហេតុអ្វីចំណុចនេះមានសារៈសំខាន់សម្រាប់អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ?

ទិន្នន័យស្តីពីការចោទប្រកាន់អំពើជួញដូរមនុស្ស (នៅពេលបង្ហាញជានិន្នាការពី ៣-៥ ឆ្នាំ) បង្ហាញឱ្យឃើញថាតើការចោទប្រកាន់ទោសមានរយៈពេលយូរប៉ុណ្ណា ចាប់ពីការដាក់ពាក្យបណ្តឹងរបស់នគរបាល រហូតដល់ការបិទបញ្ចប់សំណុំរឿងក្នុងតុលាការ ថាតើមានការកកស្ទះសំណុំរឿងជួញដូរមនុស្សក្នុងតុលាការ ឬថាតើមានការប្តឹងឧទ្ធរណ៍លើសំណុំរឿងជួញដូរមនុស្សទៅតុលាការនៅកម្រិតបន្ទាប់ច្រើនដែរឬទេ។

រយៈពេលនៃចំណាត់ការលើសំណុំរឿងមួយ និងលទ្ធភាពដែលសេចក្តីសម្រេចមួយត្រូវបានប្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ ជាកត្តាសំខាន់ៗដែលជនរងគ្រោះយកមកពិចារណា នៅពេលធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ថាតើត្រូវធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្សឬទេ។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ (KPIs) ទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ១២ និង ១៦ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។



# សូចនាករ ៦-៩




## ប្រធានបទ ៖ លទ្ធផលសម្រាប់ជនរងគ្រោះ

### ហេតុអ្វីចំណុចនេះមានសារៈសំខាន់សម្រាប់អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ?

សូចនាករទិន្នន័យស្តីពីលទ្ធផលអំពើជួញដូរមនុស្ស បង្ហាញពីចំនួនសំណុំរឿងដែលត្រូវបានកត់ត្រា (ត្រូវបានផ្តន្ទាទោស ឬត្រូវបានសម្រេចឱ្យរួចខ្លួន) និងចំនួនសំណុំរឿងដែលមានការចេញសេចក្តីសម្រេចឱ្យផ្តល់សំណងជំងឺចិត្ត/បដិទាន/សំណងការខូចខាត និងសំណុំរឿងដែលជនរងគ្រោះពិតជាបានទទួលសំណងជំងឺចិត្តពីមូលនិធិសំណងជំងឺចិត្តនៅថ្នាក់ជាតិ ឬបដិទាន/សំណងការខូចខាតពីជនដែលប្រព្រឹត្តអំពើជួញដូរមនុស្ស។

លទ្ធភាពនៃការផ្តន្ទាទោសសំណុំរឿងជួញដូរមនុស្សដោយជោគជ័យ និងថាតើតុលាការនឹងចេញដីកាឱ្យផ្តល់សំណងជំងឺចិត្ត បដិទាន ឬសំណងការខូចខាតឬទេ ជាកត្តាសំខាន់ៗដែលជនរងគ្រោះនឹងយកមកពិចារណានៅពេលធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ថាតើគួរធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្សឬទេ។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ (KPIs) ទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ១៥ និង ១៦ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។



# សូចនាករ ១០-១២




## ប្រធានបទ ៖ ការផ្តល់ការគាំទ្រដល់ជនរងគ្រោះ

### ហេតុអ្វីចំណុចនេះមានសារៈសំខាន់សម្រាប់អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ?

សូចនាករទិន្នន័យស្តីពីអំពើជួញដូរមនុស្សទាំងនេះបង្ហាញពីចំនួនសំណុំរឿងជួញដូរមនុស្ស ដែលជនរងគ្រោះទទួលបានជំនួយផ្នែកច្បាប់ ដើម្បីយល់ពីសិទ្ធិរបស់ពួកគេ (ចំណុចនេះអាចកើតឡើងនៅដំណាក់កាលផ្សេងៗក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ) ថាតើជនរងគ្រោះអាចថតទុកសក្ខីកម្មរបស់ពួកគេក្នុងនាមជាសាក្សី នៅមុនការជំនុំជម្រះ និងថាតើមានដំណើរការច្បាស់លាស់សម្រាប់ការដាក់បណ្តឹងស្តីពីរបៀបប្រតិបត្តិចំពោះជនរងគ្រោះនៅដំណាក់កាលណាមួយក្នុងដំណើរការដោះស្រាយសំណុំរឿងជួញដូរមនុស្ស ឬទេ។

សំណុំទិន្នន័យនីមួយៗមានសារៈសំខាន់សម្រាប់ឱ្យជនរងគ្រោះធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវថាតើគួរធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្ស ឬទេ។ ជំនួយផ្នែកច្បាប់ និងសមត្ថភាពក្នុងការផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីដែលត្រូវបានថតទុកជាមុន ជាវិធីក្នុងការកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តដែលកើតមានជាញឹកញាប់ចំពោះជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ ការផ្តល់ការណែនាំដល់ជនរងគ្រោះស្តីពីយន្តការដោះស្រាយបណ្តឹងសាធារណៈ បង្ហាញថាមានស្តង់ដារនៃការប្រតិបត្តិដែលគួរធានាឱ្យបាន ប្រសិនបើជនរងគ្រោះសម្រេចចិត្តធ្វើជាសាក្សីក្នុងសំណុំរឿងជួញដូរមនុស្ស។

ព័ត៌មានបន្ថែមស្តីពីរបៀបអនុវត្តសូចនាករទាំងនេះ ដែលផ្តោតលើការផ្តល់ការគាំទ្រដល់ជនរងគ្រោះ មានបង្ហាញ ក្នុងគោលការណ៍ណែនាំសម្រាប់តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ (KPIs) ទាំងនេះបង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ១១ និង ១៤ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។



# សូចនាករ ១៣-១៦




## ប្រធានបទ ៖ ទម្រង់នៃអំពើជួញដូរមនុស្ស និងទិន្នន័យបែងចែកតាមជនរងគ្រោះ

### ហេតុអ្វីចំណុចនេះមានសារៈសំខាន់សម្រាប់អភិក្រមយកចិត្តទុកដាក់លើជនរងគ្រោះ?

ការប្រមូលទិន្នន័យដោយបែងចែកតាមភេទ អាយុ និងពិការភាព មានសារៈសំខាន់សម្រាប់ការស្វែងយល់ពីអត្តសញ្ញាណរបស់ជនរងគ្រោះ និងប្រភេទនៃការគាំទ្រដែលពួកគេត្រូវការចាំបាច់។

ការប្រើប្រាស់ កម្រងសំណួរខ្លីរបស់ក្រុមវ៉ាស៊ីនតោន (Washington Group Short Set of questions on functioning) ស្តីពីការបំពេញមុខងារ នឹងក្រើនរំលឹកដល់តុលាការ ស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអំពីជំនួយជាក់លាក់ដែលជនមានពិការភាពអាចត្រូវការចាំបាច់។ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីអំពើជួញដូរមនុស្ស បានលើកឡើងពីសារៈសំខាន់នៃការប្រមូលទិន្នន័យស្តីពីស្ថានភាពពិការភាពដល់សម័យប្រជុំលើកទី ២៤ របស់គណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិជនពិការ៖

*ភាពប្រសព្វគ្នានៃពិការភាព និងអំពើជួញដូរមនុស្ស ជាផ្នែកមួយដែលត្រូវបានមើលរំលងក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តជាអន្តរជាតិពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស។ បញ្ហានេះគួរត្រូវបានចាត់ទុកជាបញ្ហាបន្ទាន់ចំពោះមុខ។ បច្ចុប្បន្ន មិនសូវមានទិន្នន័យបែងចែកជាប្រភេទស្តីពីបទពិសោធន៍របស់ជនដែលមានពិការភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៃទម្រង់នៃការកេងប្រវ័ញ្ចនោះទេ។ ចំណុចនេះនាំឱ្យមានកង្វះការយកចិត្តទុកដាក់ កង្វះការយល់ដឹង និងកង្វះការអនុវត្តល្អ។*

សំណុំទិន្នន័យ បានពីកម្រងសំណួរខ្លីរបស់ក្រុមវ៉ាស៊ីនតោន ដែលគួរយកមកពិចារណានៅពេលកំណត់អត្តសញ្ញាណជនរងគ្រោះ និងដែលត្រូវបានប្រើប្រាស់ជាសកលក្នុងជំរឿន និងសកម្មភាពប្រមូលទិន្នន័យនានារបស់ការិយាល័យស្ថិតិផ្សេងទៀត រួមមាន ៖

- តើអ្នកមានការលំបាកក្នុងការមើល ឬទេ?
- តើអ្នកមានការលំបាកក្នុងការស្តាប់ ឬទេ?
- តើអ្នកមានការលំបាកក្នុងការដើរ ឬធ្វើបំលាស់ទី ឬទេ?
- តើអ្នកមានការលំបាកក្នុងការយល់ ឬផ្តោតអារម្មណ៍ ឬទេ?
- តើអ្នកមានការលំបាកក្នុងការធ្វើឱ្យអ្នកដទៃយល់ពីអ្នក ឬទេ?

ព័ត៌មានបន្ថែមស្តីពីរបៀបអនុវត្តសូចនាករទាំងនេះ ដែលផ្តោតលើការផ្តល់ការគាំទ្រដល់ជនរងគ្រោះ មានបង្ហាញក្នុងគោលការណ៍ណែនាំសម្រាប់តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ (KPIs) ទាំងនេះ បង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ៥, ១២, ១៤ និង ១៦ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។



# សូចនាករ ១៧-២២




**ប្រធានបទ ៖ តម្លាភាពនៃទិន្នន័យស្តីពីអំពើជួញដូរមនុស្ស ដើម្បីកសាងការយល់ដឹងរបស់សាធារណជន ដៃគូរដ្ឋាភិបាល និងដៃគូមិនមែនរដ្ឋាភិបាលដែលកំពុងខិតខំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

## ហេតុអ្វីចំណុចនេះមានសារៈសំខាន់សម្រាប់វិធីសាស្ត្រយកចិត្តទុកដាក់លើជនរងគ្រោះ?

សូចនាករទិន្នន័យស្តីពីអំពើជួញដូរមនុស្ស មានសារៈសំខាន់ ព្រោះអនុសញ្ញា ACTIP គឺជាអនុសញ្ញាថ្នាក់តំបន់ ដែលតម្រូវឱ្យមានការចែករំលែកទិន្នន័យគន្លឹះស្តីពីអំពើជួញដូរមនុស្ស ដើម្បីធានាការសម្រេចគោលបំណងនៃអនុសញ្ញានេះ។ ការបោះពុម្ពផ្សាយទិន្នន័យនិន្នាការ ៣-៥ ឆ្នាំឱ្យបានទាន់ពេលវេលានៅដំណាច់ឆ្នាំនីមួយៗ នឹងផ្តល់ព័ត៌មានកាន់តែប្រសើរដល់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងតុលាការជាដៃគូក្នុងការអនុវត្តអនុសញ្ញា ACTIP។

ព័ត៌មានបន្ថែមស្តីពីរបៀបអនុវត្តសូចនាករទាំងនេះ ដែលផ្តោតលើការផ្តល់ការគាំទ្រដល់ជនរងគ្រោះ មានបង្ហាញក្នុង<u>គោលការណ៍ណែនាំសម្រាប់តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ</u>។

ទិន្នន័យសូចនាករសមិទ្ធិគន្លឹះ ( KPIs) ទាំងនេះបង្ហាញពីការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ៨, និង ១១-១៦ នៃអនុសញ្ញាអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ គឺជាលទ្ធផលនៃការពិភាក្សា និងការទំនាក់ទំនងតាមអ៊ីមែលជាច្រើនលើកច្រើនសារជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ក្នុងប្រទេសកម្ពុជា ឡាវ ហ្វីលីពីន ថៃ និងវៀតណាម។ រដ្ឋសមាជិកអាស៊ានដទៃទៀត បានដឹងពីដំណើរការនេះតាមរយៈតំណាងរបស់ខ្លួនក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន (SOMTC)។

<u>កម្មវិធី ASEAN-ACT</u> នឹងបន្តធ្វើការងារជាមួយអាស៊ាន និងរដ្ឋសមាជិក ដើម្បីពង្រឹងអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញា ACTIP ក៏ដូចជាបង្កើនគុណភាព និងតម្លាភាពទិន្នន័យស្តីពីអំពើជួញដូរមនុស្ស។



កម្ពុជា



ឥណ្ឌូនេស៊ី



ឡាវ



ហ្វីលីពីន



ថៃ



វៀតណាម

